ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ១៦៩/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

ដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ ឯកឧត្តម អេម៉ានុយអែល ម៉ាក្រុង
ប្រធានាធិបតី នៃសាធារណរដ្ឋបារាំង នៅព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ១៤-១៦ ខែវិច្ឆិកា ឆ្នាំ ២០២៦

តបតាមការអញ្ជើញរបស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តម អេម៉ានុយអែល ម៉ាក្រុង** ប្រធានាធិបតី នៃសាធារណរដ្ឋបារាំង អមដោយ**លោកជំទាវទីមួយ ប្រ៊ីហ្សីត ម៉ាក្រុង** បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២៦។

ដំណើរទស្សនកិច្ចជាប្រវត្តិសាស្ត្រនេះ ជាដំណើរទស្សនកិច្ចផ្លូវរដ្ឋលើកដំបូង របស់ប្រធានាធិបតីបារាំងមកប្រទេសកម្ពុជា ក្នុងរយៈពេល ៦០ឆ្នាំ បន្ទាប់ពីដំណើរទស្សនកិច្ចរបស់ **ឯកឧត្តមប្រធានាធិបតី ហ្សាល ដឺហ្គោល** មករាជធានីភ្នំពេញ ក្នុងឆ្នាំ១៩៦៦ និងជាងបីទសវត្សរ៍ ក្រោយដំណើរទស្សនកិច្ចរបស់ **ឯកឧត្តមប្រធានាធិបតី ហ្វ្រង់ស្វ័រ មីតេរ៉ង់** ក្នុងឆ្នាំ១៩៩៣។ ដំណើរទស្សនកិច្ចនេះ បានបង្ហាញពីចំណងមិត្តភាពដ៏យូរអង្វែង ការជឿទុកចិត្តគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំង។

ដំណើរទស្សនកិច្ចនេះប្រព្រឹត្តទៅក្នុងពេលវេលាដ៏មានសារៈសំខាន់ជាពិសេសមួយ ស្របពេលដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ និងបានទទួលតំណែងជាប្រធានកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី។ ដំណើរទស្សនកិច្ចនេះ ក៏បានឆ្លុះបញ្ចាំងផងដែរ អំពីភាពរឹងមាំនៃភាពជាដៃគូយូរអង្វែង រវាងប្រទេសទាំងពីរដែលមានមូលដ្ឋានតាមរយៈចំណងប្រវត្តិសាស្ត្ររួម ការគោរពគ្នាទៅវិញទៅមក និងការប្តេជ្ញាចិត្តរួមគ្នាចំពោះសន្តិភាព ពហុភាគីនិយម ការគោរពច្បាប់អន្តរជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។

បន្ទាប់ពីពិធីស្វាគមន៍ជាផ្លូវការ **ឯកឧត្តមប្រធានាធិបតី** និង**លោកជំទាវទីមួយ** បានចូលបង្គំគាល់ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង។ **ព្រះករុណា ព្រះមហាក្សត្រ** ក៏បានសព្វព្រះរាជហឫទ័យរៀបចំពិធីលៀងសាយភោជន៍ផ្លូវរដ្ឋ ជាកិត្តិយសជូន**ឯកឧត្តមប្រធានាធិបតី និងលោកជំទាវទីមួយ**ផងដែរ។ **ឯកឧត្តមប្រធានាធិបតី** បានជួបពិភាក្សាការងារជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចមហារដ្ឋាធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ជាងនេះទៀត **ឯកឧត្តមប្រធានាធិបតី** និង**លោកជំទាវ** ក៏បានអញ្ជើញដាក់កម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធនៅវិមានឯករាជ្យ នៅព្រះបរមរូប **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ»** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ជាទីបំផុត និងបាន

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ: (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

អញ្ជើញគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជនកម្ពុជា និងបារាំងដែលបានពលីជីវិត ក្នុងសង្គ្រាមលោកលើកទី១ នៅរូបសំណាកនៃរូបពីរផងដែរ។

ក្នុងឱកាសជួបពិភាក្សាជាមួយ**ឯកឧត្តមប្រធានាធិបតី ម៉ាក្រុង សម្តេចតេជោប្រធានព្រឹទ្ធសភា** បានថ្លែងអំណរគុណចំពោះភាពកក់ក្តៅ និងសុច្ឆន្ទៈរបស់**ឯកឧត្តមប្រធានាធិបតី** និង**លោកជំទាវទីមួយ** ដែលបានធ្វើឱ្យប្រជាជនកម្ពុជា មានអារម្មណ៍រំភើបយ៉ាងខ្លាំង។ ជាការឆ្លើយតប **ឯកឧត្តមប្រធានាធិបតីបារាំង** បានរំលឹកឡើងវិញនូវដំនួបប្រកបដោយផ្លែផ្កាជាមួយ**សម្តេចតេជោ ហ៊ុន សែន** កាលពីឆ្នាំ២០២២ នៅសាធារណរដ្ឋបារាំង និងបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរបស់បារាំង ចំពោះចំណងមិត្តភាពដ៏យូរអង្វែង ការជឿទុកចិត្តគ្នាទៅវិញទៅមក និងការគោរពគ្នារវាងប្រទេសទាំងពីរ។ ភាគីទាំងពីរ បានផ្លាស់ប្តូរទស្សនគ្នាយ៉ាងផុសផុល អំពីមធ្យោបាយនានាក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី លើវិស័យសំខាន់ៗរួមមាន សេដ្ឋកិច្ច ពាណិជ្ជកម្ម អភិបាលកិច្ច អប់រំ និងបច្ចេកវិទ្យា ព្រមទាំងលើបញ្ហាតំបន់ និងអន្តរជាតិដែលជាផលប្រយោជន៍ និងក្តីបារម្ភរួម។

នៅក្នុងជំនួបទ្វេភាគីនៅវិមានសន្តិភាព **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និង**ឯកឧត្តមប្រធានាធិបតី** បានផ្លាស់ប្តូរយោបល់ស៊ីជម្រៅ អំពីការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-បារាំង លើវិស័យអាទិភាពដូចជា ពាណិជ្ជកម្ម និងវិនិយោគ ការពារជាតិ និងសន្តិសុខ ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ការអប់រំនិងបណ្តុះបណ្តាលសុខាភិបាល ការស្រាវជ្រាវវិទ្យាសាស្ត្រ ជាមពល បច្ចេកវិទ្យាឌីជីថលនិងបញ្ញាសិប្បនិម្មិត ព្រមទាំងការអភិរក្សនិងការស្តារឡើងវិញនូវបេតិកភណ្ឌវប្បធម៌កម្ពុជា។

ថ្នាក់ដឹកនាំទាំងពីរ បានស្វាគមន៍ចំពោះវឌ្ឍនភាពសម្រេចបានតាមរយៈកិច្ចសហប្រតិបត្តិការដែលមានស្រាប់ និងបានគូសបញ្ជាក់ជាថ្មី អំពីការប្តេជ្ញាចិត្ត ក្នុងការជំរុញការអនុវត្តគម្រោង និងគំនិតផ្តួចផ្តើមថ្មីៗ ដែលនឹងពង្រីកវិសាលភាពនៃកិច្ចសហប្រតិបត្តិការ និងបង្កើតផលប្រយោជន៍ជាក់ស្តែងជូនប្រជាជននៃប្រទេសទាំងពីរ។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានរៀបរាប់ជូនអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកែលម្អបរិយាកាសវិនិយោគ និងសម្រួលនីតិវិធីធុរកិច្ច ដើម្បីទាក់ទាញវិនិយោគបរទេសឱ្យបានកាន់តែច្រើន ជាពិសេសការវិនិយោគរបស់បារាំង។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ផងដែរ អំពីសារៈសំខាន់នៃការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យបញ្ញាសិប្បនិម្មិត ក្នុងទិសដៅធានាឱ្យបាននូវការប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវ សុវត្ថិភាព និងមានប្រយោជន៍។ ភាគីទាំងពីរ ក៏បានឯកភាពផងដែរ បន្តជំរុញគំនិតផ្តួចផ្តើមជាក់ស្តែងបន្ថែមទៀត លើវិស័យដែលមានសក្តានុពល រួមចំណែកដល់ការអភិវឌ្ឍកម្ពុជាប្រកបដោយចីរភាព និងការពង្រឹងភាពជាដៃគូទ្វេភាគីបន្ថែមទៀត។

លទ្ធផលដ៏សំខាន់មួយនៃដំណើរទស្សនកិច្ចនេះ គឺការអនុម័តសេចក្តីថ្លែងការណ៍នយោបាយរួម ដែលបានលើកកម្ពស់ទំនាក់ទំនងកម្ពុជា-បារាំង ឡើងទៅកាន់ភាពជាដៃគូថ្មីមួយកម្រិតទៀត។ សេចក្តីថ្លែងការណ៍នេះបានឆ្លុះបញ្ចាំងពីឆន្ទៈនយោបាយរួមរបស់ប្រទេសទាំងពីរ ក្នុងការពង្រឹងទំនាក់ទំនងជាប្រវត្តិសាស្ត្រ និងដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រ សម្រាប់ជំរុញកិច្ចសហប្រតិបត្តិការនាពេលអនាគតខាងមុខ ដោយផ្តោតលើវិស័យសន្តិសុខ-នយោបាយ ពាណិជ្ជកម្ម និងវិនិយោគ វប្បធម៌ អប់រំ និងបច្ចេកវិទ្យា ព្រមទាំងបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរួម ក្នុងការគោរពច្បាប់អន្តរជាតិ និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ការពង្រឹងពហុភាគីនិយមប្រកបដោយប្រសិទ្ធភាព និងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព។

បន្ទាប់ពីជំនួបពិភាក្សាប្រកបដោយផ្លែផ្កានេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និង **ឯកឧត្តមប្រធានាធិបតី ម៉ាក្រុង** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងឯកសារកិច្ចសហប្រតិបត្តិការ សរុបចំនួន ២៩ ទាំងក្នុងក្របខណ្ឌស្ថាប័នរដ្ឋ និងឯកជន នៃប្រទេសទាំងពីរ។ លិខិតុបករណ៍ទាំងនេះ គ្របដណ្តប់លើវិស័យជាច្រើនរួមមាន សេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ ថាមពល ហេដ្ឋារចនាសម្ព័ន្ធ ការពារជាតិ បច្ចេកវិទ្យានិងបញ្ញាសិប្បនិម្មិត អប់រំ សុខាភិបាល និងវប្បធម៌និងបេតិកភ័ណ្ឌ។ ឯកសារទាំងនេះ នឹងជួយពង្រឹងក្របខណ្ឌស្ថាប័ន សម្រួលដល់ការផ្ទេរចំណេះដឹងនិងបច្ចេកវិទ្យា ជួយដល់ការអភិវឌ្ឍធនធានមនុស្ស កៀរគរធនធានវិនិយោគ និងបង្កើតកាលានុវត្តភាពធុរកិច្ចថ្មីៗ ដែលកត្តាទាំងនេះនឹងរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។

នៅចុងបញ្ចប់នៃជំនួបទ្វេភាគីនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និង **ឯកឧត្តមប្រធានាធិបតីបារាំង** បានអញ្ជើញធ្វើសន្និសីទសារព័ត៌មានរួមគ្នា បង្ហាញលទ្ធផលសំខាន់ៗ នៃកិច្ចពិភាក្សា និងបានលើកឡើងសាជាថ្មីនូវទស្សនវិស័យរួមសម្រាប់អនាគតនៃទំនាក់ទំនងកម្ពុជា-បារាំង។ នៅចុងបញ្ចប់នៃបទអន្តរាគមន៍ **ឯកឧត្តមប្រធានាធិបតី អេម៉ានុយអែល ម៉ាក្រុង** បានសង្កត់ធ្ងន់ថា កម្ពុជាអាចជឿជាក់លើមិត្តភាពរបស់ប្រទេសបារាំងនៅថ្ងៃនេះ ដែលដូចអតីតកាល និងអនាគតកាល។

ព្រឹត្តិការណ៍សំខាន់មួយទៀតនៃដំណើរទស្សនកិច្ចផ្លូវរដ្ឋនេះ គឺព្រះរាជពិធីបិទបញ្ចប់គម្រោងស្តារប្រាសាទមេបុណ្យខាងលិចក្នុងតំបន់អង្គរ ជាផ្លូវការ ដែលបានប្រព្រឹត្តទៅនៅខេត្តសៀមរាប នារសៀលថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៦ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម អេម៉ានុយអែល ម៉ាក្រុង** និង**លោកជំទាវទី១ ប្រ៊ីហ្ស៊ីត ម៉ាក្រុង**។ សមិទ្ធផលដ៏ត្រចះត្រចង់នេះ មិនត្រឹមតែតំណាងឱ្យការស្តារឡើងវិញនូវមេរតកស្ថាបត្យកម្មវិសេសវិសាលនៃអរិយធម៌ខ្មែរប៉ុណ្ណោះទេ ប៉ុន្តែជានិមិត្តរូបដ៏មានអត្ថន័យសម្រាប់ចំណងមិត្តភាពរឹងមាំ និងកិច្ចសហប្រតិបត្តិការវប្បធម៌យូរអង្វែងរវាងកម្ពុជា និងបារាំង។ លើសពីនេះ សមិទ្ធផលដ៏វិសេសវិសាលនេះ បានបង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តជាបន្តបន្ទាប់របស់ប្រទេសបារាំង ក្នុងការចូលរួមអភិរក្ស ការពារ និងលើកកម្ពស់តម្លៃបេតិកភណ្ឌវប្បធម៌ ដែលមិនអាចកាត់ថ្លៃបាន។

ដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់**ឯកឧត្តមប្រធានាធិបតី អេម៉ានុយអែល ម៉ាក្រុង** បាននាំមកនូវលទ្ធផលដ៏ល្អតាមរយៈការចុះហត្ថលេខាលើកិច្ចព្រមព្រៀងដ៏ច្រើនជាឯកត្តកម្ម គ្របដណ្តប់លើវិស័យការពារជាតិ ពន្ធដារ ថាមពល បេតិកភណ្ឌវប្បធម៌ ហេដ្ឋារចនាសម្ព័ន្ធ និងពាណិជ្ជកម្ម នៅក្នុងពិធីផ្លាស់ប្តូរកិច្ចព្រមព្រៀង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និង **ឯកឧត្តមប្រធានាធិបតីបារាំង**។

ដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់**ឯកឧត្តមប្រធានាធិបតី អេម៉ានុយអែល ម៉ាក្រុង** បានបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយទៀតនៅក្នុងទំនាក់ទំនងកម្ពុជា-បារាំង និងជំរុញបន្ថែមទៀតនូវទំនាក់ទំនងទ្វេភាគីឱ្យកាន់តែរឹងមាំជាងមុន និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែទូលំទូលាយជាងមុន។ ភាពជាដៃគូថ្មីនេះ មិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់ប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែក៏បានរួមចំណែកដល់សន្តិភាព ស្ថិរភាព សន្តិសុខ និងវិបុលភាព រវាងប្រទេសទាំងពីរផងដែរ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស ២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០២៦